**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៧១៧ សសរ. កសក

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារដឹកនាំគម្រោងធ្វើឲ្យប្រសើរឡើងគុណភាពសិក្សា និងកែលម្អសាលាជាតិកសិកម្មកំពង់ចាមតាមវិធីសាស្ត្រចលនាភូមិថ្មី

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន នៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារដឹកនាំគម្រោងធ្វើឲ្យប្រសើរឡើងគុណភាពសិក្សា និងកែលម្អសាលាជាតិកសិកម្មកំពង់ចាមតាមវិធីសាស្ត្រចលនាភូមិថ្មី (Establishment of Working Group For Saemaul-Undong

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២០
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

Based Quality Improvement and Innovation Project of Kampong Cham National School of Agriculture) ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ឱម គឹមស៊ា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២- ឯកឧត្តម **ង៉ែត កុសល** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣- ឯកឧត្តម **សុខ ស៊ីឡូ** | ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- លោក **សំ ឆោមសទ្ធា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥- លោក **សួន សុធឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ៦- លោក **ព្រាប វិសារទោ** | សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ៧- លោក **ទី ចាន់ណា** | ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ៨- លោក **ជា ច័ន្ទវាសនា** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ៩- លោក **ព្រំ សុមានី** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០-លោក **សួន សេរី** | នាយកសាលាជាតិកសិកម្មកំពង់ចាម | សមាជិក |
| ១១-លោក **ថាយ សុមុនី** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល | សមាជិក |
| ១២-លោកស្រី **មាស សុទ្ធាវី** | អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ | សមាជិកា |
| ១៣-លោក **តិន សុភាព** | នាយករងសាលាជាតិកសិកម្មព្រែកលៀប | សមាជិក |
| ១៤-លោក **ប៉ុល ចាន់ធី** | ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ១៥- លោក **ម៉ុន ភារដេត** | អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ១៦- លោក **អ៊ុយ ពិសិដ្ឋ** | មន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាល | លេខាធិការ។ |

**ប្រការ២.**_

ក្រុមការងារដឹកនាំគម្រោងមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ផ្តល់ការណែនាំជាយុទ្ធសាស្ត្រសម្រាប់ជាធាតុចូលក្នុងការអនុវត្តគម្រោង
- លើកកម្ពស់កិច្ចសហការ និងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីអនុវត្តតួនាទី និងភារកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយអង្គការ KOICA ស្តីពី គម្រោងធ្វើឲ្យប្រសើរឡើងគុណភាពសិក្សា និងកែលម្អសាលាជាតិកសិកម្មកំពង់ចាមតាមវិធីសាស្ត្រ ចលនាភូមិថ្មី ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥
- ពង្រឹងសមត្ថភាពសាលាជាតិកសិកម្មកំពង់ចាមដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអប់រំ ដែលមានស្រាប់ និងបង្កើតផែនការមេដើម្បីអភិវឌ្ឍសាលាជាតិកសិកម្មកំពង់ចាម
- បង្កើតកម្មវិធីសិក្សាថ្មីដែលទាក់ទងទៅនឹងការអភិវឌ្ឍជនបទនៅកម្ពុជាតាមវិធីសាស្ត្រចលនាភូមិថ្មី
- បណ្តុះបណ្តាលអ្នកដឹកនាំជាយុវជន និងបង្កើនឱកាសការងារឲ្យយុវជនតាមរយៈការផ្តល់នូវវិធីសាស្ត្រអនុវត្តជាក់ស្តែង និងចំណេះដឹង
- ពិនិត្យលើផែនការសកម្មភាពការងារ និងផែនការថវិការបស់គម្រោងដើម្បីធានានូវសង្គតិភាព គណនេយ្យភាព និងតម្លាភាព
- ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្ត និងវឌ្ឍនភាពគម្រោងធៀបទៅនឹងគោលបំណង និងគោលដៅរបស់គម្រោង

- ពិនិត្យ និងដោះស្រាយបញ្ហានានា ដែលអាចកើតមានក្នុង និងក្រោយពេលអនុវត្តគម្រោង
- ធ្វើការផ្សព្វផ្សាយព័ត៌មាន និងគាំទ្រដល់ការដាក់បញ្ចូលបទពិសោធន៍ល្អៗរបស់គម្រោង ដល់ស្ថាប័នពាក់ព័ន្ធ និងអ្នករៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ
- រៀបចំរបាយការណ៍វឌ្ឍនភាពគម្រោងដាក់ជូនប្រធានពិនិត្យ និងសម្រេច
- រៀបចំកិច្ចប្រជុំប្រចាំឆមាស ប្រចាំឆ្នាំ ឬកិច្ចប្រជុំដទៃទៀតតាមការចាំបាច់ ។

**ប្រការ៣.-**

ប្រធានក្រុមការងារដឹកនាំគម្រោង មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវរួមលើការងារដឹកនាំ សម្របសម្រួល និងផ្តល់គោលនយោបាយរបស់គម្រោង
- មានសិទ្ធិចុះហត្ថលេខាលើលិខិតរដ្ឋបាល កំណត់ហេតុប្រជុំ និងឯកសារផ្សេងៗរបស់គម្រោង
- ធ្វើជាអធិបតីក្នុងអង្គប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗ
- មានសិទ្ធិអញ្ជើញស្ថាប័នពាក់ព័ន្ធ ឬអ្នកជំនាញដែលពាក់ព័ន្ធចូលរួមប្រជុំ ក្នុងករណីចាំបាច់
- ទទួលខុសត្រូវលើការងារផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៤.-**

ក្រុមការងារដឹកនាំគម្រោងមានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលត្រូវដឹកនាំដោយប្រធានមួយរូប និងមានសមាជិក សមាជិកាមួយចំនួនជាជំនួយការតាមការចាំបាច់។ លេខាធិការដ្ឋាននេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជានាទិករភាពនៃដំណើរការការងាររដ្ឋបាលទូទៅរបស់ក្រុមការងារដឹកនាំគម្រោង
- រៀបចំកម្មវិធីប្រជុំ និងកម្មវិធីចុះពិនិត្យការងារអនុវត្តគម្រោងនៅទីតាំងគម្រោង
- រៀបចំផែនការសកម្មភាព និងថវិការបស់លេខាធិការដ្ឋាន និងក្រុមការងារដឹកនាំគម្រោង
- ទទួលខុសត្រូវលើការងារផ្សេងៗទៀតដែលប្រធាន និងអនុប្រធានប្រគល់ជូន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាត់ចែងរបស់ប្រធាន អនុប្រធានក្រុមការងារដឹកនាំគម្រោង។

**ប្រការ៥.-**

អនុប្រធាន សមាជិក សមាជិកា និងលេខាធិការក្រុមការងារដឹកនាំគម្រោង ត្រូវបំពេញភារកិច្ចតាមជំនាញរបស់ខ្លួន និងតាមការប្រគល់សិទ្ធិជូនពីប្រធានក្រុមការងារដឹកនាំគម្រោង។

**ប្រការ៦.-**

អនុប្រធាន សមាជិក សមាជិកា និងលេខាធិការក្រុមការងារដឹកនាំគម្រោង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។ ក្នុងករណីប្រធាន អវត្តមាន អនុប្រធានត្រូវដឹកនាំកិច្ចប្រជុំ ។

**ប្រការ៧.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ថ្នាក់ដឹកនាំក្រសួង
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ